# ផែនការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេក-វិទ្យាគមនាគមន៍ និងព័ត៌មាន ឆ្នាំ២០១៧ និង ២០១៨

"ធ្វើឱ្យប្រសើរឡើងនូវបរិយាកាសនវានុវត្តន៍ និងការចាប់ផ្តើមជំនួញក្នុងវិស័យប.គ.ព. "

## មាតិកា


១. សេចក្តីផ្តើម

២. គោលដៅ និងសកម្មភាពអាទិភាព

៣.កាលវិភាគនៃការអនុវត្តផែនការ

៤. ការតាមដានត្រួតពិនិត្យការអនុវត្តគម្រោង

៥.ឧបសម្ព័ន្ធ

៦. ឯកសារយោង

## ១. សេចក្តីផ្តើម

ផែនការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍក្នុងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ប.គ.ព.) បានរៀបចំឡើងដើម្បីប្រើប្រាស់មូលនិធិការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍ លើវិស័យ ប.គ.ព សម្រាប់បំពេញសកម្មភាពស្របតាមកម្មវត្ថុដែលមានចែងក្នុងអនុក្រឹត្យស្តីពីការកំណត់យន្តការគ្រប់គ្រងផែនការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។ ក្នុងនោះ អនុក្រឹត្យស្តីពីការកំណត់យន្តការគ្រប់គ្រងផែនការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានបានចង្អុលបង្ហាញថាមូលនិធិអាចត្រូវប្រើប្រាស់សម្រាប់៖

- ការកសាងហេដ្ឋារចនាសម្ព័ន្ធមជ្ឈមណ្ឌលនវានុវត្តន៍ មន្ទីរពិសោធន៍ ឬបន្ទប់ពិសោធន៍បម្រើឱ្យការអប់រំ ការបណ្តុះបណ្តាល ការស្រាវជ្រាវ និងការអភិវឌ្ឍ និងនវានុវត្តន៍លើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យា-គមនាគមន៍និងព័ត៌មាន
- ការអប់រំនិងការបណ្តុះបណ្តាលលើជំនាញទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ការសិក្សាស្រាវជ្រាវ ការអភិវឌ្ឍ និងនវានុវត្តន៍លើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ការគាំទ្រដល់ការបង្កើតអាជីវកម្មនិងសេវាកម្មថ្មីៗលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ការផ្តល់អាហារូបករណ៍ដល់សិស្ស និស្សិតផ្នែកទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ការបង្កើតព្រឹត្តិការណ៍និងកម្មវិធីផ្សេងៗក្នុងគោលបំណងអភិវឌ្ឍធនធានមនុស្ស និងការធ្វើឱ្យកាន់តែប្រសើរឡើងនូវការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍លើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យា-គមនាគមន៍ និងព័ត៌មាន
- ការបង្កើតកម្មវិធីប្រកួតប្រជែងទំនើបកម្មនៃបច្ចេកវិទ្យានិងភាពជាសហគ្រិនផ្តើមលើវិស័យទូរគមនាគមន៍និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

នៅក្នុងឆ្នាំ២០១៧ និង២០១៨ ផែនការកសាងសមត្ថភាព មានគោលបំណង ជំរុញការកសាងសមត្ថភាព បណ្តុះបណ្តាលធនធានមនុស្ស នវានុវត្តន៍ ក្នុងវិស័យ ប.គ.ព. ជាជំហានឈានទៅកការសម្រេចគោលដៅដែលមានចែងក្នុងគោលនយោបាយ អភិវឌ្ឍន៍វិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ឆ្នាំ២០២០ ដែលក្នុងនោះ សិស្សានុសិស្សបញ្ចប់មធ្យមសិក្សាទុតិយភូមិទាំងអស់នឹងត្រូវទទួលបានការបណ្តុះបណ្តាលបំណិនវិជ្ជាជីវៈផ្នែក ប.គ.ព. និស្សិតចាប់យកជំនាញនេះក៏ត្រូវកើនឡើងស្មើនឹង ១៥% នៃជំនាញទាំងអស់ រីឯអ្នកបច្ចេកទេសក្នុងវិស័យ ប.គ.ព. សម្រាប់ការស្រាវជ្រាវ និងអភិវឌ្ឍន៍នឹងកើនឡើងដល់៣០នាក់ក្នុងចំណោមប្រជាជន ១លាននាក់ ហើយអ្នកស្រាវជ្រាវក្នុងវិស័យនេះ នឹងកើនដល់ចំនួន១០នាក់ក្នុង១លាននាក់។ ការអភិវឌ្ឍធនធានមនុស្សនេះ ក៏ដើម្បីរៀបចំប្រែក្លាយឧស្សាហកម្ម ប.គ.ព. គឺជាឧស្សាហកម្មយុទ្ធសាស្ត្រសម្រាប់អនាគតរបស់កម្ពុជាស្របតាមការកំណត់របស់រាជរដ្ឋាភិបាល ក្នុងគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម។

ក្រៅពីនេះ ផែនការនេះមានគោលបំណងធ្វើអោយប្រសើរឡើងនូវបរិយាកាសនវានុវត្តន៍ និងការបង្កើតជំនួញថ្មី ខាងផ្នែកបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ជាជំហ៊ានឈានទៅកការផ្តល់ការងារកាន់តែច្រើនទាក់ទាញបរិមាណសិស្ស-និស្សិតចាប់យកនិងពង្រឹងជំនាញ ប.គ.ព. របស់ខ្លួនជាបន្តបន្ទាប់ទៀត។ ក្រៅពីការផ្តល់ការងារ

នៅក្នុងស្រុក ការបង្កើតជំនួញថ្មីគឺជានិន្នាការវិវត្តនៃការវិនិយោគខាងផ្នែកបច្ចេកវិទ្យា ព្រមទាំងឱកាសដែលកើតមានឡើងក្នុងតំបន់និងពិភពលោកនាពេលបច្ចុប្បន្ន។ ការដាក់ទុនវិនិយោគលើក្រុមហ៊ុនបច្ចេកវិទ្យាបង្កើតថ្មីក្នុងតំបន់អាស៊ីអាគ្នេយ៍កំពុងកើនឡើងជាលំដាប់ ហើយអាចជាទំពក់ក្នុងការទាក់ទាញការវិនិយោគបន្ថែមពីខាងក្រៅ។ លំហូរទុនវិនិយោគមកលើក្រុមហ៊ុនបច្ចេកវិទ្យាបង្កើតថ្មីក្នុងតំបន់អាស៊ីអាគ្នេយ៍បានកើនឡើងពី **២៨១លានដុល្លារ** ក្នុងឆ្នាំ ២០១២ ដល់ជាង **៦,៤ ពាន់លានដុល្លារ** ក្នុងឆ្នាំ២០១៧(CBInsights 9/13/2017)។ នៅក្នុងនោះប្រទេសជាច្រើនក្នុងតំបន់មានដូចសិង្ហបុរី ឥណ្ឌូនេស៊ី ម៉ាឡេស៊ី វៀតណាម និងថៃ បានកំពុងនាំមុខក្នុងការទទួលទុនវិនិយោគច្រើនជាងគេ។ ដោយឡែកប្រទេសកម្ពុជា ឋិតនៅលំដាប់ជួរក្រោយបំផុតក្នុងការចាប់យកឱកាសទាំងនេះ។ ការជំរុញការតភ្ជាប់រវាងការបណ្តុះបណ្តាលធនធានមនុស្ស នវានុវត្តន៍ និងការបង្កើតជំនួញថ្មី គឺជាគោលបំណងប្រទាក់ក្រឡាសំដៅដល់ការរៀបចំដើម្បីអភិវឌ្ឍន៍ឧស្សាហកម្មមួយនេះបន្តទៅអនាគតប្រកបដោយចីរភាព។

## ២. គោលដៅ និងសកម្មភាពអាទិភាព

ដើម្បីសម្រេចបានគោលបំណងខាងលើ ផែនការនេះត្រូវបានរៀបចំដើម្បីសម្រេចបានគោលដៅដូចខាងក្រោម៖

- ជំរុញការអភិវឌ្ឍធនធានមនុស្សខាងផ្នែកបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ជំរុញការស្រាវជ្រាវ និងអភិវឌ្ឍន៍ នវានុវត្តន៍ក្នុងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ជំរុញការបង្កើតអាជីវកម្មថ្មីៗខាងផ្នែកបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

សកម្មភាពអាទិភាពដែលបានកំណត់ចេញសម្រាប់អនុវត្តដើម្បីសម្រេចគោលដៅរៀបចំឡើងតាមសេចក្តីខ្វះខាតជាក់ស្តែងដូចបានសិក្សាលម្អិតក្នុងការវិភាគគោលនយោបាយអភិវឌ្ឍន៍វិស័យ ទ-ប.គ.ព និងពីកិច្ចពិភាក្សារវាងអ្នកពាក់ព័ន្ធ ដូចជាក្រសួងអប់រំ សិស្សានុសិស្ស អ្នកស្រាវជ្រាវ និងអ្នកជំនួញជាដើម។

**១.)ជំរុញការអភិវឌ្ឍធនធានមនុស្សខាងផ្នែកបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន**

| ល.រ | សកម្មភាពអាទិភាព | គម្រោង |
|---|---|---|
| 1 | ផ្សៀងផ្ទាត់តម្រូវការជំនាញ និងទីផ្សារបច្ចេកវិទ្យា ប.គ.ព. នៅកម្ពុជា | គម្រោងស្រាវជ្រាវពីតម្រូវការជំនាញបច្ចេកវិទ្យាប.គ.ព. នៅកម្ពុជា<br>គម្រោងសិក្សាពីទីផ្សារបច្ចេកវិទ្យា ប.គ.ព. នៅកម្ពុជា |
| 2 | ធ្វើឲ្យប្រសើរឡើងនូវកម្មវិធីសិក្សាខាងផ្នែកបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន | គម្រោងអភិវឌ្ឍន៍ឬកែលម្អកម្មវិធីសិក្សាខាងផ្នែកបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានគ្រប់កម្រិត |
| 3 | ពង្រីកហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការបណ្តុះបណ្តាលបច្ចេកវិទ្យា ប.គ.ព. នៅតាមមធ្យមសិក្សា | - គម្រោងសិក្សារៀបចំផែនការបំពាក់បន្ទប់រៀនកុំព្យូទ័រនៅតាមមធ្យមសិក្សា<br>- បង្កើតថ្នាក់រៀន ប.គ.ព. នៅតាមមធ្យមសិក្សា |
| 4 | ជំរុញការសិក្សាតាមប្រព័ន្ធអេឡិកត្រូនិក | គម្រោងបញ្ចូលមុខវិជ្ជាសិក្សាទៅក្នុងប្រព័ន្ធប.គ.ព<br>( Digitalizing Highshool Educational Contents ) |
| 5 | បង្កើនចំនួននិស្សិតចាប់យកមុខវិជ្ជាជំនាញ ប.គ.ព. និងការស្រាវជ្រាវមុខជំនាញ ប.គ.ព. | ការផ្តល់អាហារូបករណ៍ថ្នាក់ជំនាញ ប.គ.ព. (កម្រិតបរិញ្ញាបត្រ និងកម្រិតជំនាញ និងកម្រិតអនុបណ្ឌិត)<br>( Bachelor and Master Degree Scholarships for Telecommunication and ICT students ) |

| | | |
|---|---|---|
| 6 | ជំរុញការផ្តល់ជំនាញ ប.គ.ព. ជាក់ស្តែង សម្រាប់និស្សិតជំនាញ | បង្កើតកម្មវិធីបណ្តុះបណ្តាលជំនាញ ប.គ.ព. តាមទិដ្ឋភាពការងារជាក់ស្តែង និងកម្មវិធីចុះកម្មសិក្សា (ICT BootCamp and Internship) |

## ២.) ជំរុញការស្រាវជ្រាវ និងអភិវឌ្ឍន៍ នវានុវត្តន៍ ខាងផ្នែក ប.គ.ព.

| ល.រ | សកម្មភាពអាទិភាព | គម្រោង |
|---|---|---|
| 1 | ការកសាងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការស្រាវជ្រាវ និងអភិវឌ្ឍន៍ក្នុងវិស័យ ប.គ.ព. | សាងសង់មជ្ឈមណ្ឌលនវានុវត្តន៍ សម្រាប់ការស្រាវជ្រាវនិងអភិវឌ្ឍន៍លើវិស័យ ប.គ.ព. ព្រមទាំងបន្ទប់ពិសោធន៍នានា (Establishing ICT Innovation Center and ICT Labs for specifics purpose) |
| 2 | លើកទឹកចិត្តការស្រាវជ្រាវនិងអភិវឌ្ឍន៍ខាងផ្នែក ប.គ.ព. និងជំរុញការផ្ទេរបច្ចេកវិទ្យា | ជំរុញដំណើរការចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម ការគ្រប់គ្រងប្រកាសនីយបត្រតក្កកម្ម ព្រមទាំងជំរុញការផ្ទេរបច្ចេកវិទ្យានៅតាមសាកលវិទ្យាល័យនិងស្ថាប័នស្រាវជ្រាវនានា (Promoting Patent Registration and Technology Transfer) |
| 3 | ពិពិធកម្មការងារស្រាវជ្រាវខាងផ្នែកបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន | កម្មវិធីស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាប.គ.ព. សម្រាប់អភិវឌ្ឍន៍លើវិស័យអប់រំ សុខាភិបាល គមនាគមន៍ កសិកម្ម និងឧស្សាហកម្ម (ICT R&D Research Grants for Education, Health, Telecom Agriculture and Industry ) |

## ៣.) ជំរុញការបង្កើតអាជីវកម្មថ្មីៗលើវិស័យ ប.គ.ព.

| ល.រ | សកម្មភាពអាទិភាព | គម្រោង |
|---|---|---|
| 1 | រៀបចំសម្របសម្រួលដំណើរការចុះបញ្ជីក្រុមហ៊ុនប.គ.ព. ឲ្យកាន់តែមានភាពងាយស្រួលឡើង | រៀបចំសម្រួលដំណើរការចុះបញ្ជីក្រុមហ៊ុន ប.គ.ព. ថ្មី តាមច្រកចេញ-ចូលតែមួយ (Establishment of Single Window for ICT Business Registration) |
| 2 | ជំរុញការប្រលងប្រជែងធុរកិច្ចខាងផ្នែកប.គ.ព. | រៀបចំប្រកួតប្រជែងពានរង្វាន់ធុរកិច្ចលើវិស័យ ICT (ICT Awards) |
| 3 | ជំរុញការផ្តល់ទុនដល់ក្រុមហ៊ុនបង្កើតថ្មីខាងផ្នែកប.គ.ព. | ការផ្តល់មូលនិធិសម្រាប់ការបង្កើតក្រុមហ៊ុន ប.គ.ព ថ្មី (Seed Funding Program) |
| 4 | ជំរុញការពង្រីកមុខរបរក្នុងប្រទេស ថ្នាក់តំបន់ និងលើឆាកអន្តរជាតិ | រៀបចំកម្មវិធីបង្កើតបណ្តាញទំនាក់ទំនងរវាងអាជីវកម្មថ្មីទៅក្នុងថ្នាក់តំបន់ និងឆាកអន្តរជាតិ (Networking Event/National or International Fairs) |
| 5 | ជំរុញការប្រែក្លាយគំរូផលិតផលទៅជាមុខជំនួញ | កម្មវិធីបណ្តុះបណ្តាល ឬកម្មវិធីប្រឹក្សាលើការបង្កើតមុខរបរថ្មីខាងផ្នែកបច្ចេកវិទ្យា (Coaching and Mentoring Program on Business development or Enterpreneurship) |

## ៣.កាលវិភាគនៃការអនុវត្តផែនការ

| | 2017 | | 2018 | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
| ផ្សព្វផ្សាយ | | | | | | | | | | | | | | |
| បើកទទួលសំណើសុំ | | | | | | | | | | | | | | |
| អនុម័តសំណើសុំ | | | | | | | | | | | | | | |
| ផ្សព្វផ្សាយសេចក្តីសម្រេច | | | | | | | | | | | | | | |
| ការអនុវត្តគម្រោង | | | | | | | | | | | | | | |
| ការត្រួតពិនិត្យ | | | | | | | | | | | | | | |
| ការផាត់ទាត់២០% (២០១៧ & ២០១៨) | | | | | | | | | | | | | | |
| រៀបចំផែនការបន្ត | | | | | | | | | | | | | | |

## ៤.ការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តផែនការនិងគម្រោង

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការនេះ ត្រូវបានភ្ជាប់ជាមួយនឹងការតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តគម្រោងដែរ ដែលក្នុងនោះ៖

- មន្ត្រីលេខាធិការដ្ឋាន នឹងចុះត្រួតពិនិត្យលើគម្រោងដែលកំពុងអនុវត្ត ឬគម្រោងដែលបញ្ចប់រួចដើម្បីផ្ទៀងផ្ទាត់ទៅលើលទ្ធផលតាមដំណាក់កាល។ ការពិនិត្យឃើញភាពមិនប្រក្រតីកើតឡើងខុសពីការរំពឹងទុកក្នុងសំណើសុំអនុវត្តគម្រោង លេខាធិការដ្ឋានមានសិទ្ធិស្នើសុំផ្អាកការអនុវត្តគម្រោងទៅក្រុមប្រឹក្សាភិបាលមូលនិធិ។
- ចំពោះគម្រោងដែលមានទំហំធំ និងប្រើប្រាស់អស់ថវិកាច្រើន ហើយមានបច្ចេកទេសខ្ពស់ លេខាធិការដ្ឋានមានសិទ្ធិជួលទីប្រឹក្សាសម្រាប់អង្កេតតាមដានការអនុវត្ត និងត្រួតពិនិត្យលើលក្ខណៈបច្ចេកទេសទាំងនោះ។
- របាយការណ៍វឌ្ឍនភាពនៃការអនុវត្តគម្រោងទាំងនោះ ហើយនឹងបញ្ហាប្រឈមនានានៃការអនុវត្តផែនការនេះ នឹងត្រូវដាក់ជូនក្រុមប្រឹក្សាភិបាលមូលនិធិស.អ. ពិនិត្យសម្រេចក្នុងកិច្ចប្រជុំប្រចាំត្រីមាស។

## ៥.ឧបសម្ព័ន្ធ

-ការវិភាគពីបរិយាកាសនៃការបង្កើតមុខជំនួញថ្មីក្នុងវិស័យប.គ.ព. និងបញ្ហាប្រឈម
-សេចក្តីណែនាំពីការស្នើសុំអនុវត្តគម្រោង
-គំរូសំណើសុំអនុវត្តគម្រោង( Project Proposal )

## ៦.ឯកសារយោង

- គោលនយោបាយអភិវឌ្ឍន៍វិស័យទ-ប.គ.ព. ២០២០
- គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា ២០២៤
- Master Plan for Information and Communications Technology in Education, 2009-2013